ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ...៤៤៣១១.......អពដ

L202311220245TD3454

ថ្ងៃចន្ទ ១០កើត ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០២៣

# សេចក្តីណែនាំ
# ស្តីពី
# ឯកសារភស្តុតាងចំណាយសម្រាប់សហគ្រាសដែលទទួលការផ្គត់ផ្គង់ពីកសិករមិនស្ថិតក្នុងរបបស្វ័យប្រកាស

អនុលោមតាមមាត្រា១១ នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន ចំណាយដែលត្រូវបានអនុញ្ញាតឱ្យកាត់កងសម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូល គឺជាចំណាយសម្រាប់អាជីវកម្មដែលសហគ្រាសបានទូទាត់ ឬត្រូវសងក្នុងឆ្នាំជាប់ពន្ធ និងត្រូវបំពេញលក្ខខណ្ឌស្របតាមគោលការណ៍ចំណាយអាចកាត់កងបាន ក្នុងនោះភាពពិតនៃចំណាយ ត្រូវបានបញ្ជាក់អះអាងដោយភស្តុតាងដែលអាចត្រួតពិនិត្យបាន។

កន្លងមក អគ្គនាយកដ្ឋានពន្ធដារ សង្កេតឃើញថាសហគ្រាសស្ថិតក្នុងរបបស្វ័យប្រកាស បានទទួលការផ្គត់ផ្គង់ពីកសិករមិនស្ថិតក្នុងរបបស្វ័យប្រកាស ដោយមិនទទួលបានវិក្កយបត្រត្រឹមត្រូវ ឬគ្មានឯកសារភស្តុតាងបញ្ជាក់បានត្រឹមត្រូវឡើយ។ ហេតុនេះ ការកាត់កងចំណាយសម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូលមិនត្រូវបានអនុញ្ញាតឱ្យកាត់កងជាចំណាយឡើយ។

ដូច្នេះ ក្នុងគោលបំណងធានាបាននូវសង្គតិភាពក្នុងការអនុវត្ត និងក្នុងន័យជួយសម្រួលដល់សហគ្រាសដែលមានប្រតិបត្តិការផ្គត់ផ្គង់ពីកសិករ ព្រមទាំងជួយលើកកម្ពស់វិស័យកសិកម្មក្នុងស្រុក អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការណែនាំបន្ថែមអំពីឯកសារភស្តុតាងចំណាយអាចកាត់កងបានសម្រាប់សហគ្រាសដែលទទួលការផ្គត់ផ្គង់ពីកសិករ ដូចខាងក្រោម៖

១. រាល់ប្រតិបត្តិការផ្គត់ផ្គង់ដោយកសិករដែលគ្មានវិក្កយបត្រត្រឹមត្រូវ សហគ្រាសត្រូវមានលេខអត្តសញ្ញាណប័ណ្ណ ឈ្មោះនិងលេខទូរស័ព្ទរបស់អ្នកផ្គត់ផ្គង់ លើកលែងតែប្រតិបត្តិការផ្គត់ផ្គង់ម្តងម្កាល និងមានទឹកប្រាក់ក្រោម ២០០ ០០០ រៀល មិនតម្រូវឱ្យមានលេខអត្តសញ្ញាណប័ណ្ណរបស់អ្នកផ្គត់ផ្គង់ឡើយ។

២. សហគ្រាសទទួលការផ្គត់ផ្គង់ពីកសិករដូចមានចែងក្នុងចំណុច១ខាងលើ ត្រូវបញ្ចូលទិន្នន័យក្នុងបញ្ជីទិញនូវកាលបរិច្ឆេទ លេខបណ្ណចំណាយ និងទឹកប្រាក់ចំណាយ រួមទាំងលេខអត្តសញ្ញាណ-ប័ណ្ណ ឈ្មោះនិងលេខទូរស័ព្ទរបស់កសិករ នៅក្នុងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មអនឡាញ (e-Filing)។ ដោយឡែកចំណាយដែលមានទឹកប្រាក់ក្រោម ២០០ ០០០ រៀល ដែលកើតឡើងម្តងម្កាល សហគ្រាសត្រូវបញ្ចូលលេខបណ្ណចំណាយ និងលេខទូរស័ព្ទអ្នកផ្គត់ផ្គង់។



អគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (+855) 23 886 708 / ទូរសារ: (+855) 23 886 700, E-mail: gdt@tax.gov.kh, Website: www.tax.gov.kh

L202311220245TD3454

៣. សម្រាប់គោលដៅក្នុងការផ្ទៀងផ្ទាត់អនុលោមភាពសារពើពន្ធ សហគ្រាសត្រូវមានឯកសារគ្រប់គ្រងផ្ទៃក្នុងដែលអាចត្រួតពិនិត្យបាន ដូចជា៖ កិច្ចសន្យា ឯកសារបញ្ជាទិញ ឯកសារប្រគល់-ទទួលនិងឯកសារទូទាត់ប្រាក់ បណ្ណបញ្ចេញ-បញ្ចូលស្តុក បណ្ណចំណាយបេឡា បណ្ណ-ចំណាយតាមធនាគារ អត្តសញ្ញាណប័ណ្ណ(កសិករ) ព្រមទាំងបានកត់ត្រាក្នុងបញ្ជីគណនេយ្យ ដោយបញ្ជាក់ឱ្យច្បាស់លាស់អំពីចំនួនទឹកប្រាក់ និងកាលបរិច្ឆេទនៃខ្ទង់ចំណាយនោះកើតឡើង។

អគ្គនាយកដ្ឋានពន្ធដារ ជឿជាក់យ៉ាងមុតមាំថា គ្រប់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ ដែលទទួលការផ្គត់ផ្គង់ពីកសិករមិនស្ថិតក្នុងរបបស្វ័យប្រកាស នឹងយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**គង់ វិបុល**